FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ
ឆ្នាំទី ២ លេខ ១៤ ខែកក្កដា ឆ្នាំ ២០០៣
ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ការប្រើប្រាស់ជីគីមីសំរាប់ដំណាំស្រូវ

សារធាតុចិញ្ចឹមខនិជ N, P និង K ជាសារធាតុ ដ៏សំខាន់ក្នុងចំណោមសារធាតុចិញ្ចឹមផ្សេងៗទៀត ដែលរុក្ខជាតិត្រូវការដើម្បីទ្រទ្រង់ការលូតលាស់ និងផ្តល់ផ្លែផ្ការបស់វា។ ដីភាគច្រើននៅប្រទេសកម្ពុជា ជាពិសេសដីសំរាប់ដំណាំស្រូវពុំអាចផ្គត់ផ្គង់សារធាតុចិញ្ចឹម ខនិជ ទាំងនេះឱ្យបានគ្រប់គ្រាន់តាមតំរូវការរបស់ដំណាំឡើយ។ ដូច្នេះដើម្បីធានាបាននូវការលូតលាស់ជាប្រក្រតីរបស់ដំណាំ គេចាំបាច់ត្រូវតែបាចជីបន្ថែមឱ្យបានត្រឹមត្រូវទៅតាមតំរូវការរបស់ដំណាំ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមបទដ្ឋានបច្ចេកទេសដើម្បីជៀសវាងនូវការខាតបង់ថវិកា ពេលវេលា និងផលប៉ះពាល់ដល់បរិស្ថាន។ ម្យ៉ាងទៀត បរិមាណជីដែលត្រូវប្រើ ក៏អាស្រ័យផងដែរទៅនឹងប្រភេទដី ពូជដំណាំ របបទឹក និងកត្តាបរិស្ថាន ផ្សេងៗទៀត។

ខាងក្រោមនេះគឺជាអនុសាសន៍ នៃការប្រើប្រាស់ជីគីមីលើដំណាំស្រូវ ដែលដាំដុះលើ "**ក្រុមដីបាកាន**" នៃតំបន់ទំនាបអាស្រ័យទឹកភ្លៀងនៅប្រទេសកម្ពុជា។

ក្រុមដីបាកាន កកើតឡើងលើតំបន់ទំនាបល្បាប់ចាស់ ដែលមានកំណើតមកពីសំណឹកនៃសារធាតុផ្សេងៗពីតំបន់ភ្នំ និងដីល្បាប់ពីទន្លេ។ ពេលមានទឹកជំនន់ធំ តំបន់នៃដីនេះតែងតែទទួលដីល្បាប់ពីជំនន់ទន្លេ ឬ បឹងដែរ។ គេប្រទះឃើញក្រុមដីនេះគ្រប់ទីកន្លែង នៃតំបន់ធ្វើស្រែក្នុងប្រទេសកម្ពុជា ហើយតាមការប៉ាន់ស្មានក្រុមដីនេះ មានប្រមាណ ១០-១៥% នៃផ្ទៃដីដាំស្រូវសរុប។ នៅតំបន់ដែលមិនទាន់មានការរុករានធ្វើស្រែ គេតែងតែសង្កេតឃើញមានព្រៃត្រូពិចក្រាស់ល្មមដុះលូតលាស់ លើប្រភេទដីនេះ ។



(សូមមើលរូបភាព)

## កំរិតប្រើប្រាស់ជីគីមី ក្នុងលក្ខខណ្ឌទូទៅ សំរាប់ក្រុមដីបាកាន មានដូចខាងក្រោម៖

**១-កំរិតណែនាំទី ១** (ប្រើសំរាប់ពូជទំនើប)៖ **៧៥:៣០:០-៣០** (N, $P_2O_5$, $K_2O$, គ.ក្រ /ហ.ត) ដែលត្រូវបាចដូចតទៅ៖

✧ **ជីទ្រាប់បាត**

- អ៊ុយរ៉េ (Urea) : ១៣៨ គ.ក្រ/ហ.ត
- ដេ អា ប៉េ (DAP) : ៦៥ គ.ក្រ/ហ.ត
- ប៉ូតាស្យូ (KCl) : ០-៥០ គ.ក្រ/ហ.ត

✧ **ជីបំប៉នលើកទី ១** (បាច ៣០ ថ្ងៃក្រោយស្ទូង) : បាចជីអ៊ុយរ៉េចំនួន ៦៥ គ.ក្រ/ហ.ត

✧ **ជីបំប៉នលើកទី ២** (បាចពេលកំណកំណើតកួរ) : បាចជីអ៊ុយរ៉េចំនួន ៤៩ គ.ក្រ/ហ.ត

**២-កំរិតណែនាំទី ២** (ប្រើសំរាប់ពូជប្រពៃណី)៖ **៦០:២០:០-២០** (N, $P_2O_5$, $K_2O$, គ.ក្រ /ហ.ត) ដែលត្រូវបាចដូចតទៅ៖

✧ **ជីទ្រាប់បាត**

- អ៊ុយរ៉េ (Urea) : ១១៣ គ.ក្រ/ហ.ត
- ដេ អា ប៉េ (DAP) : ៤៣ គ.ក្រ/ហ.ត
- ប៉ូតាស្យូ (KCl) : ០-៣៣ គ.ក្រ/ហ.ត

✧ **ជីបំប៉នលើកទី ១** (បាច ៣០ ថ្ងៃក្រោយស្ទូង) : បាចជីអ៊ុយរ៉េចំនួន ៥២ គ.ក្រ/ហ.ត

✧ **ជីបំប៉នលើកទី ២** (បាចពេលកំណកំណើតកួរ) : បាចជីអ៊ុយរ៉េចំនួន ៣៩ គ.ក្រ/ហ.ត

ចំពោះដីប្រភេទនេះ ការប្រើប្រាស់ជីអាសូត (N) និងផូស្វ័រ (P) តែងតែទទួលបានលទ្ធផលល្អ ប៉ុន្តែចំលើយតបទៅលើជីប៉ូតាស្យូម មានលក្ខណៈទាប និងមានការប្រែប្រួលទៀតផង។ ចំលើយតបទៅនឹង ជីប៉ូតាស្យូម នៅមានកំរិតក្នុងលក្ខខណ្ឌដាំដុះមិនគាប់ប្រសើរ ហើយបើនៅលើដីដែលមានជីជាតិល្អនៃក្រុមដីបាកាន ការដាក់ជីប៉ូតាស្យូមពុំស្តែងចេញនូវប្រសិទ្ធភាពរបស់វាទេ។ ក្នុងករណីនេះពុំគួរប្រើ ជីប៉ូតាស្យូមទេ ប៉ុន្តែបើក្នុងលក្ខខណ្ឌធម្មតាគេអាចប្រើជីប៉ូតាស្យូមរហូតដល់មួយបាវក្នុងមួយហិកតា។ ក្នុងលក្ខខ័ណ្ឌនៃការដាំដុះដែលមានលក្ខណៈប្រពលវប្បកម្ម រយៈពេលប្រហែល ៥ឆ្នាំ ការប្រើប្រាស់ជី K អាចមានប្រសិទ្ធភាព។ ប្រសិនបើតំលៃផលស្រូវខ្ពស់ ហើយស្រែមានទឹកគ្រប់គ្រាន់សំរាប់ដាំដុះនោះគេគួរប្រើកំរិតជី N និង P អោយបានខ្ពស់នៅលើដីប្រភេទនេះ (១២០:៦០:៣០)។ ពូជទំនើបតែងតែផ្តល់ ទិន្នផលខ្ពស់ជាងពូជប្រពៃណីនៅលើដីប្រភេទនេះ ទោះបីជាដាក់ ឬ មិនដាក់ជីក៏ដោយ។ កំរិតជីណែនាំខ្ពស់គឺប្រើសំរាប់តែការដាំដុះពូជស្រូវទំនើបប៉ុណ្ណោះ។

សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិទ្យាសាស្ត្រដី និងទឹក មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ឬការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ.
ទូរស័ព្ទលេខ៖(៨៥៥-២៣) ៦៣១៩ ៦៩៣-៤ ទូរអក្ខរ: cardi@cardi.org.kh វែបសាយ: www.cardi.org.kh
VSeng@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh